ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការផ្ទុះជំងឺជ្រូកគ្រុនចៀកខៀវ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមប្រកាសជូនដំណឹងដល់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទូទាំងប្រទេសឱ្យបានជ្រាបថា ថ្មីៗនេះមានផ្ទុះជំងឺជ្រូកគ្រុនចៀកខៀវនៅតំបន់មួយចំនួនក្នុងខេត្តកំពង់ចាម ខេត្តស្វាយរៀង និងខេត្តសៀមរាប បណ្តាលឱ្យមានជ្រូកឈឺនិងងាប់មួយចំនួន។

ចំពោះបាតុភាពនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសដាក់តំបន់ផ្ទុះជំងឺជ្រូកគ្រុនចៀកខៀវនៅក្នុងខេត្តទាំង៣ ស្របតាមខ្លឹមសារនៃអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ និងចាត់មន្ត្រីជំនាញបសុព្យាបាល និងមន្ទីរកសិកម្មខេត្តពាក់ព័ន្ធចាត់វិធានបង្ការ-ទប់ស្កាត់ការរាលដាលតាមរយៈការអនុវត្តវិធានជីវសុវត្ថិភាពនៅតាមកសិដ្ឋាន និងកន្លែងចិញ្ចឹមជ្រូកក្នុងតំបន់ផ្ទុះជំងឺ ដោយផ្អាកជាបណ្តោះអាសន្នការទិញ ការលក់ និងការដឹកជញ្ជូនជ្រូករស់ចូល-ចេញ ឬឆ្លងកាត់កន្លែងផ្ទុះជំងឺនិងចុះអន្តរាគមន៍ព្យាបាលសត្វឈឺ បាញ់ថ្នាំសម្លាប់មេរោគ និងអប់រំ-ផ្សព្វផ្សាយដល់កសិដ្ឋាន និងប្រជាពលរដ្ឋចូលរួមទប់ស្កាត់ការចម្លងមេរោគ ដែលរហូតមកដល់ពេលនេះស្ថានភាពរាលដាលជំងឺស្ថិតក្រោមការគ្រប់គ្រងទាំងស្រុង។

ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺជ្រូកគ្រុនចៀកខៀវពីខេត្តមួយទៅខេត្តមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមប្រកាសជាសាធារណៈជូនដល់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ចូលរួមសហការ និងចាត់វិធានការទប់ស្កាត់រាល់ចលនាសត្វអនាធិបតេយ្យនិងការនាំចូលសត្វជ្រូកដោយគ្មានច្បាប់អនុញ្ញាតបណ្តាលឱ្យប៉ះពាល់ដល់សុខភាពសត្វនិងសុខភាពសាធារណៈ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សង្ឃឹមយ៉ាងមុតមាំថា បងប្អូនប្រជាពលរដ្ឋ អាជីវករ និងអាជ្ញាធរដែនដីព្រមទាំងសមត្ថកិច្ចគ្រប់ជាន់ថ្នាក់សហការអនុវត្តតាមសេចក្តីប្រកាសព័ត៌មាននេះឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ ២០១៥

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320